អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ....០២៦........អ.ស.ហ.ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជីបរធនបាលកិច្ច
- បានទទួលការឯកភាពពីក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងសម័យប្រជុំនាថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៥

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌ និងនីតិវិធីក្នុងការត្រួតពិនិត្យលើភាពរឹងមាំហិរញ្ញវត្ថុ និងកាតព្វកិច្ចផ្សេងៗរបស់ក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតពីនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល ឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនបរធនបាល ដែលទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតពី **ន.ប.ធ.** ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

វាក្យសព្ទដែលប្រើនៅក្នុងប្រកាសនេះ មាននិយមន័យ ដូចខាងក្រោម៖

**ការតម្រូវពង្រឹងការគ្រប់គ្រងអាជីវកម្ម** (Requirements to Improve Business Management) សំដៅដល់ការតម្រូវឱ្យក្រុមហ៊ុនបរធនបាលពង្រឹងការគ្រប់គ្រង នៅពេលអនុបាតមូលធនសុទ្ធរបស់ក្រុមហ៊ុនបរធនបាលនោះ ធ្លាក់ក្រោម ១២០ (មួយរយម្ភៃ) ភាគរយ ដូចមានចែងនៅក្នុងប្រការ២៩ នៃប្រកាសនេះ។

**ការបញ្ជាពង្រឹងការគ្រប់គ្រងអាជីវកម្ម** (Orders to Improve Business Management) សំដៅដល់ការបញ្ជាឱ្យក្រុមហ៊ុនបរធនបាលពង្រឹងការគ្រប់គ្រង នៅពេលអនុបាតមូលធនសុទ្ធរបស់ក្រុមហ៊ុននោះធ្លាក់ក្រោម ១០០ (មួយរយ) ភាគរយ ដូចមានចែងនៅក្នុងប្រការ៣០ នៃប្រកាសនេះ។

**កិច្ចព្រមព្រៀងកម្ចីម៉ាជីន** (Marginal Loan Agreement) សំដៅដល់កម្ចីដែលចងភ្ជាប់ជាមួយរូបិយវត្ថុផ្ទាល់របស់អ្នកខ្ចី ដើម្បីទិញមូលបត្រ និងមានសុវត្ថិភាពដោយសារសាច់ប្រាក់និងមូលបត្រដែលតម្កល់ដោយអ្នកខ្ចី ត្រូវបានទទួលស្គាល់ដោយអ្នកផ្តល់កម្ចី។ ជាធម្មតា អ្នកផ្តល់កម្ចីយល់ព្រមផ្តល់កម្ចីតាមចំនួនដែលអាស្រ័យលើមូលបត្រដែលបានតម្កល់ដោយអ្នកខ្ចី។

**ខ្ទង់ក្រៅតារាងតុល្យការ** ( Off-Balance Sheet Items ) សំដៅដល់ខ្ទង់ទាំងឡាយណាដែលមិនបង្ហាញក្នុងតារាងតុល្យការ ប៉ុន្តែនាំឱ្យមានហានិភ័យលំហូរសាច់ប្រាក់អនាគត។

**មូលធនភាគហ៊ុនិក** ( Shareholders' Equity ) សំដៅដល់ទ្រព្យសកម្មដែលនៅសល់ចុងក្រោយបន្ទាប់ពីបានដកបំណុលទាំងអស់ចេញពីទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុនបរធនបាល ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS)។

**លក្ខខណ្ឌចាប់បង្ខំសងរួម** (Cross Default) សំដៅដល់លក្ខខណ្ឌក្នុងកិច្ចសន្យាផ្តល់កម្ចីដែលការពារផលប្រយោជន៍ឥណទាយក ដោយចែងពីករណីកូនបំណុលខកខានមិនបានបំពេញកាតព្វកិច្ចស្របតាមកិច្ចសន្យាផ្តល់កម្ចីណាមួយ ធ្វើឱ្យកើតឡើងនូវការខកខានមិនបានបំពេញកាតព្វកិច្ចលើបំណុលផ្សេងទៀតដោយស្វ័យប្រវត្តិ។

**លក្ខខណ្ឌហាមឃាត់ការខ្ចីប្រាក់បន្ថែម** ( Negative Pledge ) សំដៅដល់លក្ខខណ្ឌក្នុងកិច្ចសន្យាផ្តល់កម្ចី ដែលហាមឃាត់កូនបំណុលមិនឱ្យខ្ចីបំណុលបន្ថែមដោយគ្មានការយល់ព្រមពីឥណទាយក។

**ហានិភ័យដុល** ( Gross Risk ) សំដៅដល់ហានិភ័យរួមសរុបដោយរាប់បញ្ចូលទាំងហានិភ័យទីផ្សារ ហានិភ័យឥណទាន និងហានិភ័យប្រតិបត្តិការ។

**ហានិភ័យទីផ្សារ** ( Market Risk ) សំដៅដល់ហានិភ័យដែលជះឥទ្ធិពលដល់ការវិនិយោគហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល ដែលបង្កឡើងដោយសារបម្រែបម្រួលឡើងចុះនៃតម្លៃទីផ្សាររបស់អត្រាការប្រាក់ អត្រាប្តូរប្រាក់ និងមូលបត្រដែលអាចជួញដូរបានរួមមាន ភាគហ៊ុន និងសញ្ញាបណ្ណ ជាដើម។

**ហានិភ័យឥណទាន** ( Credit Risk ) សំដៅដល់ហានិភ័យដែលជះឥទ្ធិពលលើក្រុមហ៊ុនបរធនបាល ដែលបង្កឡើងដោយសារការរំលោភកិច្ចសន្យាទូទាត់សងប្រាក់កម្ចីរបស់សមភាគី។

**ហានិភ័យប្រតិបត្តិការ** ( Operational Risk ) សំដៅដល់ឱកាសខាតបង់ដែលជះឥទ្ធិពលលើក្រុមហ៊ុនបរធនបាល បង្កឡើងដោយកំហុសឆ្គងដំណើរការផ្ទៃក្នុង ការគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធមិនល្អ ឬព្រឹត្តការណ៍ ឬបុព្វហេតុខាងក្រៅ។

**អនុបាតមូលធនសុទ្ធ** ( Net Capital Ratio ) សំដៅដល់ផលធៀបជាភាគរយរវាងមូលធនប្រតិបត្តិការសុទ្ធ និងហានិភ័យដុល។

**អនុសាសន៍ពង្រឹងការគ្រប់គ្រងអាជីវកម្ម** ( Recommendation to Improve Business Management ) សំដៅដល់ ការផ្តល់អនុសាសន៍ដល់ក្រុមហ៊ុនបរធនបាល ឱ្យពង្រឹងការគ្រប់គ្រងនៅពេលអនុបាតមូលធនសុទ្ធរបស់ក្រុមហ៊ុននោះ ធ្លាក់ក្រោម ១៥០ (មួយរយហាសិប) ភាគរយ ដូចមានចែងនៅក្នុងប្រការ២៨ នៃប្រកាសនេះ។

**ឥណទេយ្យមិនមែនពាណិជ្ជកម្ម** ( Non-Trading Receivables ) សំដៅដល់សាច់ប្រាក់ដទៃទៀតដែលសមភាគីជំពាក់ក្រុមហ៊ុនបរធនបាលក្រៅពីឥណទេយ្យពាណិជ្ជកម្ម។

**ឥណទេយ្យពាណិជ្ជកម្ម** ( Trading Receivables ) សំដៅដល់លាភការដែលអតិថិជនជំពាក់សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចរបស់អតិថិជនដែលរួមទាំងកម្រៃជើងសា ឬថ្លៃសេវាផ្សេងៗ។

## ជំពូកទី២
## លក្ខខណ្ឌតម្រូវលើមូលធនភាគហ៊ុនិក

**ប្រការ៤.-**

ក្រុមហ៊ុនបរធនបាល ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដាគណនេយ្យ និងបទប្បញ្ញត្តិពាក់ព័ន្ធ និងត្រូវគណនាអនុបាតមូលធនសុទ្ធដោយអនុលោមតាមប្រកាសនេះ។

**ប្រការ៥.-**

ក្រុមហ៊ុនបរធនបាល ត្រូវរក្សាមូលធនភាគហ៊ុនិកគ្រប់ពេលវេលាមិនឱ្យតិចជាងលក្ខខណ្ឌតម្រូវលើមូលធនអប្បបរមាដែលបានកំណត់ក្នុងប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច។

ក្នុងករណីមូលធនភាគហ៊ុនិកធ្លាក់ក្រោមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ក្រុមហ៊ុនបរធនបាលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.មូ.ក.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលមូលធនភាគហ៊ុនិកធ្លាក់ក្រោមលក្ខខណ្ឌតម្រូវ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុចុងក្រោយ និងវិធានការដំណោះស្រាយរបស់ក្រុមហ៊ុនបរធនបាល។

**ប្រការ៦.-**

ក្រុមហ៊ុនបរធនបាល ត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវប្រាក់តម្កល់ធានាអាជីវកម្ម ដែលបានកំណត់ក្នុងប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច។

ក្រុមហ៊ុនបរធនបាល មិនត្រូវប្រើប្រាស់ប្រាក់តម្កល់ធានាអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ធ្វើជាការធានាផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្ម លើកលែងតែការដកសម្រាប់ប្រើប្រាស់ក្នុងគោលបំណងដូចមានកំណត់ក្នុងប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងមានការអនុញ្ញាតពី **ន.មូ.ក.**។

**ប្រការ៧.-**

ក្រុមហ៊ុនបរធនបាលត្រូវជូនដំណឹងភ្លាមមក **ន.មូ.ក.** ដោយភ្ជាប់មកជាមួយនូវវិធានការដំណោះ-ស្រាយរបស់ក្រុមហ៊ុន ក្នុងករណីក្រុមហ៊ុនមិនអាចបំពេញ ឬដឹងថាមិនអាចបំពេញកាតព្វកិច្ចដូចមានចែងក្នុងប្រការ៦ និងកថាខណ្ឌទី២ នៃប្រការ៨ នៃប្រកាសនេះ។

## ជំពូកទី៣
## លក្ខខណ្ឌតម្រូវលើអនុបាតមូលធនសុទ្ធ

**ប្រការ៨.-**

ក្រុមហ៊ុនបរធនបាល ត្រូវគណនាអនុបាតមូលធនសុទ្ធជាប្រចាំខែតាមរូបមន្ត ដូចខាងក្រោម៖

អនុបាតមូលធនសុទ្ធ = មូលធនប្រតិបត្តិការសុទ្ធ ៖ ហានិភ័យដុល



ស.វ.ស

ក្រុមហ៊ុនបរធនបាលត្រូវរក្សាអនុបាតមូលធនសុទ្ធរបស់ខ្លួនមិនឱ្យទាបជាង ១៥០ (មួយរយហាសិប) ភាគរយ។

ក្រុមហ៊ុនបរធនបាល មិនត្រូវធ្វើប្រតិបត្តិការណាមួយដែលអាចបណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការនេះ។

## ជំពូកទី៤

## លក្ខខណ្ឌតម្រូវលើមូលធនប្រតិបត្តិការសុទ្ធ

### ប្រការ៩.-

ក្រុមហ៊ុនបរធនបាលត្រូវគណនាមូលធនប្រតិបត្តិការសុទ្ធ ដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ តាមរូបមន្ត ដូចខាងក្រោម៖

មូលធនប្រតិបត្តិការសុទ្ធ = ទ្រព្យសកម្មរយៈពេលខ្លីសរុប – បំណុលសរុប

### ប្រការ១០.-

ទ្រព្យសកម្មរយៈពេលខ្លីស្របតាមប្រកាសនេះ រួមមាន៖

១-សាច់ប្រាក់ និងទ្រព្យសកម្មទាំងអស់ស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដែលអាចបំលែងជាសាច់ប្រាក់បានក្នុងរយៈពេល ១ (មួយ) ខែ។

២-ប្រាក់តម្កល់ធានាអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការ៦ នៃប្រកាសនេះ។

៣- មូលបត្រកាន់កាប់ដោយក្រុមហ៊ុនបរធនបាលដែលបានបំពេញលក្ខខណ្ឌ និងត្រូវបានវាយតម្លៃស្របតាមប្រការ១១ នៃប្រកាសនេះ។

៤-ទ្រព្យសកម្មផ្សេងទៀតដែលកំណត់ដោយ **ន.ម.ធ.**។

ទ្រព្យសកម្មដែលមិនត្រូវបានចាត់ចូលជាទ្រព្យសកម្មរយៈពេលខ្លីស្របតាមប្រកាសនេះរួមមាន៖

១-កម្ចីដែលផ្តល់ឱ្យ ឬគណនីឥណទេយ្យដែលនឹងទទួលពីភាគហ៊ុនិក បរធនបាលរូបវន្តបុគ្គល បុគ្គលិកជាន់ខ្ពស់ និយោជិត និងបុគ្គលមានទំនាក់ទំនងពិសេសរបស់ពួកគេ និងបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនបរធនបាល។

២-ទ្រព្យអរូបិយ។

៣-ទ្រព្យសកម្មផ្សេងទៀតដែលកំណត់ដោយ **ន.ម.ធ.**។

### ប្រការ១១.-

ក្រុមហ៊ុនបរធនបាល អាចរាប់បញ្ចូលមូលបត្រដែលបានកាន់កាប់ជាទ្រព្យសកម្មរយៈពេលខ្លីបាន និងត្រូវវាយតម្លៃ ដូចខាងក្រោម៖

១-មូលបត្រកម្មសិទ្ធិដែលនឹងត្រូវចុះបញ្ជីនៅផ្សារមូលបត្រប្រតិស្រុតនៅព្រះរាជាណាចក្រកម្ពុជា ដែលក្រុមហ៊ុនបានធ្វើបរិវិសកម្ម ត្រូវវាយតម្លៃមិនលើសពី ៧០ (ចិតសិប) ភាគរយនៃថ្លៃធ្វើបរិវិសកម្ម។

២-មូលបត្រកម្មសិទ្ធិដែលបានចុះបញ្ជី និងត្រូវបានជួញដូរដោយជោគជ័យក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃចុងក្រោយនៃថ្ងៃជួញដូរនៅក្នុងទីផ្សារមូលបត្រប្រតិស្រុតនៅព្រះរាជាណាចក្រកម្ពុជា ត្រូវវាយតម្លៃមិនលើសពី ៨០ (ប៉ែតសិប) ភាគរយនៃថ្លៃទីផ្សារបច្ចុប្បន្នរបស់មូលបត្រកម្មសិទ្ធិនោះ។

៣-មូលបត្របំណុលដែលនឹងត្រូវចុះបញ្ជីនៅទីផ្សារមូលបត្រប្រតិស្រុតនៅព្រះរាជាណាចក្រកម្ពុជា ដែលក្រុមហ៊ុនបានធ្វើបរិវិសកម្ម ត្រូវវាយតម្លៃមិនលើសពី ៦០ (ហុកសិប) ភាគរយនៃថ្លៃធ្វើបរិវិសកម្ម។

៤-មូលបត្របំណុលដែលបានចុះបញ្ជី និងត្រូវបានជួញដូរដោយជោគជ័យក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃចុងក្រោយនៃថ្ងៃជួញដូរនៅក្នុងទីផ្សារមូលបត្រប្រតិស្រុតនៅព្រះរាជាណាចក្រកម្ពុជា ត្រូវវាយតម្លៃមិនលើសពី ៧០ (ចិតសិប) ភាគរយនៃថ្លៃទីផ្សារបច្ចុប្បន្នរបស់មូលបត្របំណុលនោះ។

៥-សញ្ញាបណ្ណដែលត្រូវបានចាត់ថ្នាក់ជាកម្រិតវិនិយោគ (Investment Grade Bond) និងសញ្ញាបណ្ណដែលធានាដោយរាជរដ្ឋាភិបាលកម្ពុជា ត្រូវវាយតម្លៃមិនលើសពី ៨០ (ប៉ែតសិប) ភាគរយនៃថ្លៃទីផ្សារបច្ចុប្បន្នរបស់សញ្ញាបណ្ណនោះ។

៦-មូលបត្ររដ្ឋត្រូវវាយតម្លៃមិនលើសពី ៩០ (កៅសិប) ភាគរយនៃថ្លៃទីផ្សារបច្ចុប្បន្ន។

ក្រុមហ៊ុនបរធនបាល អាចរាប់បញ្ចូលមូលបត្រផ្សេងទៀតដែលបានកាន់កាប់ជាទ្រព្យសកម្មរយៈពេលខ្លីបានតាមការកំណត់របស់ **ន.ម.ធ.**។

## ប្រការ១២.-

ដើម្បីគណនាមូលធនប្រតិបត្តិការសុទ្ធ ក្រុមហ៊ុនបរធនបាលត្រូវកាត់បន្ថយពីទ្រព្យសកម្មរយៈពេលខ្លីនូវធាតុមួយចំនួន ដូចខាងក្រោម៖

១-សំវិធានធនសម្រាប់បំណុលអាក្រក់។

២-ធាតុផ្សេងទៀតដែលកំណត់ដោយ **ន.ម.ធ.**។

ក្រុមហ៊ុនបរធនបាល ត្រូវផ្តល់ជូន **ន.ម.ធ.** នូវគោលនយោបាយផ្ទៃក្នុងស្តីពីការគ្រប់គ្រងបំណុល និងការប៉ាន់ស្មានសំវិធានធនសម្រាប់បំណុលអាក្រក់ ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានការអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។ នៅពេលមានការកែប្រែគោលនយោបាយនេះ ក្រុមហ៊ុនបរធនបាល ត្រូវផ្តល់ជូន **ន.ម.ធ.** នូវគោលនយោបាយថ្មីដោយភ្ជាប់មកជាមួយនូវការបញ្ជាក់លើចំណុចដែលត្រូវបានកែប្រែក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានការអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។ **ន.ម.ធ.** អាចពិនិត្យឡើងវិញនូវគោលនយោបាយនេះ និងតម្រូវឱ្យក្រុមហ៊ុនបរធនបាលបង្កើនកម្រិតសំវិធានធនសម្រាប់បំណុលអាក្រក់។

## ប្រការ១៣.-

ក្រុមហ៊ុនបរធនបាលត្រូវបង្ហាញរាល់ខ្ទង់ក្រៅតារាងតុល្យការដល់ **ន.ម.ធ.**។ **ន.ម.ធ.** អាចកំណត់កម្រិតនៃការកាត់បន្ថយលើទ្រព្យសកម្មរយៈពេលខ្លី ក្នុងការគណនាមូលធនប្រតិបត្តិការសុទ្ធសម្រាប់ខ្ទង់ក្រៅតារាងតុល្យការ។

**ប្រការ១៤.-**

**ន.ម.ធ.** អាចកែប្រែលក្ខខណ្ឌសម្រាប់ការគ្រប់គ្រងហានិភ័យណាមួយ ដូចមានចែងក្នុងប្រការ១១ និងប្រការ១២ នៃប្រកាសនេះ បន្ទាប់ពីវាយតម្លៃទៅតាមករណីនីមួយៗ។

**ប្រការ១៥.-**

បំណុលសរុបស្របតាមប្រកាសនេះ រួមមានៈ

១-រាល់បំណុលទាំងអស់ស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

២-បំណុលជាយថាហេតុទាំងអស់ ទោះបីជាបំណុលទាំងនោះមិនត្រូវបានបង្ហាញលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាលក៏ដោយ។

៣-ធាតុផ្សេងទៀតដែលកំណត់ដោយ **ន.ម.ធ.**។

**ប្រការ១៦.-**

ក្រុមហ៊ុនបរធនបាលអាចដកបំណុលបំពេញលើដើមទុនចេញពីបំណុលសរុបបាន លុះត្រាតែបានបំពេញលក្ខខណ្ឌ ដូចខាងក្រោមៈ

១-បំណុលបំពេញលើដើមទុននោះត្រូវមានរយៈពេលឥណប្រតិទានយ៉ាងតិច ២ (ពីរ) ឆ្នាំ។

២-ទំហំសរុបនៃបំណុលបំពេញលើដើមទុនទាំងអស់មិនត្រូវលើសពី ៥០ (ហាសិប) ភាគរយនៃមូលធនភាគហ៊ុនិក។

៣-កិច្ចសន្យាបំណុលបំពេញលើដើមទុនត្រូវស្ថិតក្នុងទម្រង់ដែលភ្ជាប់លក្ខខណ្ឌមួយចំនួន ដូចខាងក្រោមៈ

ក-ឥណទាយកបំណុលបំពេញលើដើមទុនមិនត្រូវទាមទារ ឬទទួលពីក្រុមហ៊ុនបរធនបាលនូវការទូទាត់បំណុលបំពេញលើដើមទុនតាមរយៈការទូទាត់ជាសាច់ប្រាក់ ឬការកាត់កង ឬតាមវិធីសាស្ត្រផ្សេងទៀតរហូតដល់ឥណប្រតិទាន ឬរហូតរាល់ឥណទាយកបំណុលផ្សេងទៀតទទួលបានការទូទាត់សង លើកលែងតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពី **ន.ម.ធ.**។

ខ-ការទាមទារទូទាត់ដោយឥណទាយកបំណុលបំពេញលើដើមទុន ត្រូវស្ថិតនៅលំដាប់រង បន្ទាប់ពីការទាមទារទូទាត់ដោយឥណទាយកបំណុលផ្សេងទៀត។

គ-សិទ្ធិទទួលប្រាក់ដើម និងការប្រាក់របស់ឥណទាយកបំណុលបំពេញលើដើមទុនក្នុងអំឡុងពេលខ្ចីបំណុល ត្រូវស្ថិតនៅលំដាប់រងបន្ទាប់ពីសិទ្ធិទទួលប្រាក់ដើម និងការប្រាក់របស់ឥណទាយកបំណុលផ្សេងទៀត។

ឃ-កាតព្វកិច្ចសងប្រាក់ដើម និងការប្រាក់នៃបំណុលបំពេញលើដើមទុនត្រូវបានព្យួរ ក្នុងករណីដែលអនុបាតមូលធនសុទ្ធរបស់ក្រុមហ៊ុនបរធនបាល ធ្លាក់ក្រោម ១៥០ (មួយរយហាសិប) ភាគរយ។

ង-ក្នុងស្ថានភាពជម្រះបញ្ជី ឬកែប្រែរចនាសម្ព័ន្ធរបស់ក្រុមហ៊ុនបរធនបាល ឥណទាយកបំណុលផ្សេងទៀត ត្រូវមានសិទ្ធិទទួលបានការទូទាត់សងទាំងអស់ មុននឹងឥណទាយកបំណុលបំពេញលើដើមទុនអាចទទួលបានការទូទាត់សងចំពោះបំណុលបំពេញលើដើមទុន។

ច-កិច្ចសន្យាបំណុលបំពេញលើដើមទុន មិនត្រូវភ្ជាប់លក្ខខណ្ឌដែលអនុញ្ញាតឱ្យឥណទាយកបំណុលបំពេញលើដើមទុន ទាមទារការទូទាត់មុនដល់ឥណប្រតិទាន ឬពន្លឿនការសងបំណុលឡើយ។

ឆ-កិច្ចសន្យាបំណុលបំពេញលើដើមទុនមិនត្រូវភ្ជាប់លក្ខខណ្ឌចាប់បង្ខំសងរួម ឬលក្ខខណ្ឌហាមឃាត់ការខ្ចីប្រាក់បន្ថែម។

ជ-ការសងបំណុលទាំងអស់ ឬមួយផ្នែកនៃបំណុលបំពេញលើដើមទុន ត្រូវបានធ្វើឡើងនៅពេលមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី **ន.ម.ធ.** ប៉ុណ្ណោះ។

**ន.ម.ធ.** អាចកំណត់ទម្រង់កិច្ចសន្យាបំណុលបំពេញលើដើមទុនផ្សេងពីនេះ។

## ជំពូកទី ៥
## លក្ខខណ្ឌតម្រូវលើហានិភ័យដុល

### ប្រការ១៧._

ក្រុមហ៊ុនបរធនបាលត្រូវគណនាហានិភ័យដុល ដូចមានក្នុងប្រការ៨ ស្របតាមប្រកាសនេះ តាមរូបមន្តដូចខាងក្រោម៖

ហានិភ័យដុល = ហានិភ័យទីផ្សារ + ហានិភ័យឥណទាន + ហានិភ័យប្រតិបត្តិការ

### ប្រការ១៨._

ក្រុមហ៊ុនបរធនបាលត្រូវគណនាហានិភ័យទីផ្សារ ដូចមានក្នុងប្រការ១៧ ស្របតាមប្រកាសនេះ ដោយបញ្ចូលហានិភ័យ ដូចខាងក្រោម៖

១-ហានិភ័យភាគហ៊ុន (Stock Risk)។

២-ហានិភ័យអត្រាការប្រាក់ (Interest Rate Risk)។

៣-ហានិភ័យអត្រាប្តូរប្រាក់ (Foreign Exchange Risk)។

៤-ហានិភ័យផ្សេងទៀតដែលកំណត់ដោយ **ន.ម.ធ.**។

ក្រុមហ៊ុនបរធនបាល ដែលមានបំណងប្រើប្រាស់ម៉ូឌែលផ្ទៃក្នុងរបស់ក្រុមហ៊ុនដើម្បីគណនាហានិភ័យទីផ្សារ ត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ម.ធ.**។

### ប្រការ១៩._

ក្រុមហ៊ុនបរធនបាលត្រូវគណនាហានិភ័យភាគហ៊ុន ដូចមានក្នុងប្រការ១៨ ស្របតាមប្រកាសនេះលើជាតុដែលកាន់កាប់ដោយក្រុមហ៊ុនបរធនបាលស្ថិតក្នុងលក្ខខណ្ឌ ដូចខាងក្រោម៖



ផ្ទះ. ៤

១-មូលបត្រកម្មសិទ្ធិដែលបានចុះបញ្ជី ឌីប៉ូស៊ីតធើរីរីស៊ីប លើកលែងភាគហ៊ុនបុរិមាដែលមានភាគលាភអប្បបរមាថេរនិងត្រូវបានជូនដំណឹងជាសាធារណៈ ឬមូលបត្រកម្មសិទ្ធិផ្សេងទៀត។

២-សញ្ញាបណ្ណអាចប្តូរបាន សញ្ញាបណ្ណមានភាគហ៊ុនធានា ឬមូលបត្របំណុលមានវត្ថុធានាដែលជាកម្មវត្ថុនៃការគណនាហានិភ័យភាគហ៊ុន។

៣-មូលបត្របំណុលដែលបានចុះបញ្ជីនៅទីផ្សារមូលបត្រប្រតិស្រុត។

៤-មូលនិធិដែលបានចុះបញ្ជីនៅទីផ្សារមូលបត្រប្រតិស្រុត (Exchange Traded Fund) ដែលមានទ្រព្យសកម្មនៅក្នុងមូលនិធិនោះជាកម្មវត្ថុនៃការគណនាហានិភ័យភាគហ៊ុន។

៥-ឧបករណ៍និស្សន្ទដែលមានទ្រព្យសកម្មដើមជាកម្មវត្ថុនៃការគណនាហានិភ័យភាគហ៊ុន។

៦-ធាតុផ្សេងទៀតដែលកំណត់ដោយ **ន.ម.ធ.**។

ក្រុមហ៊ុនបរធនបាលត្រូវធ្វើចំណាត់ថ្នាក់ភាគហ៊ុន សន្ទស្សន៍ភាគហ៊ុន ផលបត្រភាគហ៊ុន មូលបត្រកម្មសិទ្ធិ និងមូលនិធិទៅតាមស្ថានភាពប្រទេស និងទីផ្សារមូលបត្រដែលមូលបត្រទាំងនោះបានចុះបញ្ជីជាមួយដើម្បីគណនាហានិភ័យភាគហ៊ុន។

ក្រុមហ៊ុនបរធនបាលត្រូវគណនាហានិភ័យភាគហ៊ុនដោយរាប់បញ្ចូលទាំងហានិភ័យជាក់លាក់ និងហានិភ័យទូទៅដែលវិធីសាស្ត្រគណនា ត្រូវបានកំណត់ដោយ **ន.ម.ធ.**។

## ប្រការ២០.-

ក្រុមហ៊ុនបរធនបាល ត្រូវគណនាហានិភ័យអត្រាការប្រាក់ ដូចមានក្នុងប្រការ១៨ ស្របតាមប្រកាសនេះ លើធាតុដែលកាន់កាប់ដោយក្រុមហ៊ុនបរធនបាលស្ថិតក្នុងលក្ខខណ្ឌ ដូចខាងក្រោម៖

១-សញ្ញាបណ្ណដែលមានអត្រាគូប៉ុងថេរឬអណ្តែត។

២-មូលបត្របំណុលជាសាធារណៈ។

៣-មូលបត្របំណុលជាឯកជន។

៤-ផលបត្រពាណិជ្ជកម្ម (Commercial Paper)។

៥-មូលបត្រមានទ្រព្យធានា (Asset-Backed Securities)។

៦-ផលបត្រពាណិជ្ជកម្មមានទ្រព្យធានា (Asset-Backed Commercial Paper)។

៧-វិញ្ញាបនបត្រប្រាក់បញ្ញើ។

៨-សញ្ញាបណ្ណអាចប្តូរបាន ឬមូលបត្របំណុលមានវត្ថុធានាដែលមិនមែនជាកម្មវត្ថុនៃការគណនាហានិភ័យភាគហ៊ុន ដូចមានក្នុងប្រការ១៩ នៃប្រកាសនេះ។

៩-ឧបករណ៍និស្សន្ទដែលមានទ្រព្យសកម្មដើមជាកម្មវត្ថុនៃការគណនាហានិភ័យអត្រាការប្រាក់។

១០-ធាតុផ្សេងទៀតដែលកំណត់ដោយ **ន.ម.ធ.**។

ក្រុមហ៊ុនបរធនបាល ត្រូវគណនាហានិភ័យអត្រាការប្រាក់ ដោយរាប់បញ្ចូលទាំងហានិភ័យជាក់លាក់ និងហានិភ័យទូទៅដែលវិធីសាស្ត្រគណនាត្រូវបានកំណត់ដោយ **ន.ម.ធ.**។

**ប្រការ២១.-**

ក្រុមហ៊ុនបរធនបាលត្រូវគណនាហានិភ័យអត្រាប្តូរប្រាក់ ដូចមានក្នុងប្រការ១៨ ស្របតាមប្រកាសនេះ លើធាតុដែលកាន់កាប់ដោយក្រុមហ៊ុនបរធនបាលស្ថិតក្នុងលក្ខខណ្ឌ ដូចខាងក្រោម៖

១-ទ្រព្យសកម្ម និងបំណុលដោយរាប់បញ្ចូលទាំងខ្ទង់ក្រៅតារាងតុល្យការដែលមានរូបិយប័ណ្ណមុខងារសម្រាប់ប្រតិបត្តិការជារូបិយប័ណ្ណបរទេស។

២-ឧបករណ៍និស្សន្ទដែលមានទ្រព្យសកម្មដើមមានរូបិយប័ណ្ណមុខងារសម្រាប់ប្រតិបត្តិការទូទាត់ជារូបិយប័ណ្ណបរទេស។

៣-ធាតុផ្សេងទៀតដែលកំណត់ដោយ **ន.ម.ឆ.**។

ក្រុមហ៊ុនបរធនបាល ត្រូវគណនាហានិភ័យអត្រាប្តូរប្រាក់តាមវិធីសាស្ត្រដែលកំណត់ដោយ **ន.ម.ឆ.**។

**ប្រការ២២.-**

ក្រុមហ៊ុនបរធនបាលត្រូវគណនាហានិភ័យឥណទាន ដូចមានក្នុងប្រការ១៧ ស្របតាមប្រកាសនេះ លើធាតុដែលកាន់កាប់ដោយក្រុមហ៊ុនបរធនបាលស្ថិតក្នុងលក្ខខណ្ឌ ដូចខាងក្រោម៖

១-ប្រាក់បញ្ញើនៅធនាគារ កម្ចីគ្មានកាលកំណត់ ប្រាក់បញ្ញើមានកាលកំណត់ និងប្រាក់បញ្ញើផ្សេងទៀត។

២-ការលក់ដែលផ្សារភ្ជាប់ជាមួយកិច្ចសន្យាទិញត្រឡប់មកវិញ ឬការទិញដែលផ្សារភ្ជាប់ជាមួយកិច្ចសន្យាលក់ត្រឡប់មកវិញ។

៣-កម្ចីដែលបានផ្តល់ឱ្យអតិថិជន ឬសមភាគី។

៤-គណនីឥណទេយ្យ ចំណូលបង្ករ និងការទាមទារសំណងផ្សេងៗ។

៥-ប្រាក់ធានាសម្រាប់ភតិសន្យា ឬសិទ្ធិដែលនៅសេសសល់លើការប្រើប្រាស់ទ្រព្យសកម្មទទួលបានពីការដាក់ប្រាក់តម្កល់សម្រាប់ភតិសន្យាដែលមានរយៈពេលមិនលើសពី ៣ (បី) ខែ។

៦-ឧបករណ៍និស្សន្ទរួមមាន កិច្ចសន្យាអនាគត កិច្ចសន្យាជួញដូរទុកជាមុន និងកិច្ចសន្យាដោះដូរ។

៧-មូលបត្របំណុលជាឯកជន លើកលែងដូចខាងក្រោម៖

ក-មូលបត្របំណុលជាឯកជនដែលត្រូវបានជួញដូរក្នុងចំណោមវិនិយោគិនស្ថាប័នគុណវុឌ្ឍិ។

ខ-មូលបត្របំណុលជាឯកជនដែលចំណាត់ថ្នាក់ឥណទាន ត្រូវបានវាយតម្លៃដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង។

គ-មូលបត្របំណុលជាឯកជនដែលមានព័ត៌មានត្រូវបានលាតត្រដាង តាមវិធីសាស្ត្រជាក់លាក់របស់សមាគម និងឱកាសសម្រាប់ការធ្វើបរិវិសកម្មមូលបត្របំណុលជាឯកជននោះត្រូវបានផ្តល់ឱ្យវិនិយោគិនស្ថាប័នគុណវុឌ្ឍិជាច្រើន។

ឃ-មូលបត្របំណុលជាឯកជនដែលជាប់ពាក់ព័ន្ធនឹងភាគហ៊ុន ដោយរាប់បញ្ចូលទាំងសញ្ញាបណ្ណអាចប្តូរបាន សញ្ញាបណ្ណមានភាគហ៊ុនធានា ឬមូលបត្របំណុលមានវត្ថុធានា។

៨-កិច្ចព្រមព្រៀងកម្ចីម៉ាជីន។



ហត្ថលេខា

៩-កិច្ចសន្យាលើការគ្រប់គ្រងនិងចាត់ចែងបរធនបាលកិច្ចអចលនវត្ថុ ដើម្បីជានាការបំពេញកាតព្វកិច្ច របស់អ្នកម៉ៅការ ឬម្ចាស់ការដែលបរាជ័យក្នុងការបំពេញកាតព្វកិច្ច។

១០-ធាតុផ្សេងទៀតដែលកំណត់ដោយ **ន.ម.ធ.**។

ក្រុមហ៊ុនបរធនបាល ត្រូវគណនាហានិភ័យឥណទានដែលសមភាគីអាចនឹងមិនមានលទ្ធភាពសង ដាច់ដោយឡែកពីគ្នាតាមសមភាគីនីមួយៗ និងហានិភ័យឥណទានពាក់ព័ន្ធនឹងការធានាកាតព្វកិច្ចរបស់សមភាគីពាក់ព័ន្ធនឹងបរធនបាលកិច្ចអចលនវត្ថុដែលធ្វើប្រតិបត្តិការដោយក្រុមហ៊ុនបរធនបាល ដូចមានក្នុងចំណុចទី៩ នៃប្រការ២២ នៃប្រកាសនេះ តាមវិធីសាស្ត្រដែលកំណត់ដោយ **ន.ម.ធ.**។

ប្រសិនបើមានស្ថានភាពណាមួយដែលធ្វើឱ្យលទ្ធផលនៃហានិភ័យឥណទានអវិជ្ជមាន ដូចក្នុងកថាខណ្ឌទី២ នៃប្រការនេះ ក្រុមហ៊ុនបរធនបាលមិនត្រូវគណនាហានិភ័យឥណទាននោះទេ។

ប្រសិនបើមានស្ថានភាពណាមួយដែលជាប់ពាក់ព័ន្ធទាំងការគណនាហានិភ័យអត្រាការប្រាក់ និងហានិភ័យឥណទានរួមគ្នាលើបុគ្គលបោះផ្សាយតែមួយលើកលែងរាជរដ្ឋាភិបាល ធនាគារកណ្តាល អាជ្ញាធរខេត្ត-ក្រុង និងសហគ្រាសសាធារណៈ ដែលមានចំនួនលើសពី ២០ (ម្ភៃ) ភាគរយនៃមូលធនប្រតិបត្តិការសុទ្ធ ក្រុមហ៊ុនបរធនបាលត្រូវបញ្ចូលស្ថានភាពដែលពាក់ព័ន្ធនោះ សម្រាប់គណនាហានិភ័យឥណទានបន្ថែម តាមវិធីសាស្ត្រដែលកំណត់ដោយ **ន.ម.ធ.**។

**ប្រការ២៣.-**

ក្រុមហ៊ុនបរធនបាល ត្រូវបញ្ចូលហានិភ័យប្រតិបត្តិការដែលជាចំនួនណាមួយដែលខ្ពស់ជាងគេ ក្នុងចំណោមចំណុចទី១ និងចំណុចទី២ ដូចខាងក្រោម៖

១-ចំនួនសរុបដែលទាញចេញពីផលគុណនៃប្រាក់ចំណេញប្រតិបត្តិការប្រចាំឆ្នាំនៃអាជីវកម្មនីមួយៗ របស់ក្រុមបរធនបាលសម្រាប់រយៈពេល ៣ (បី) ឆ្នាំចុងក្រោយ ជាមួយនឹងអត្រាហានិភ័យស្មើនឹង ១៥ (ដប់ប្រាំ) ភាគរយ ឬអត្រាហានិភ័យដែលកំណត់ដោយ **ន.ម.ធ.**។ ប្រសិនបើ ប្រាក់ចំណេញប្រតិបត្តិការក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយមានចំនួនអវិជ្ជមាន នោះតម្លៃហានិភ័យប្រតិបត្តិការត្រូវបានសន្មត់ថាស្មើនឹងសូន្យ។

២-ចំនួន ១០ (ដប់) ភាគរយ នៃលក្ខខណ្ឌតម្រូវមូលធនភាគហ៊ុនិកអប្បបរមារបស់ក្រុមហ៊ុនបរធនបាល ដូចមានចែងក្នុងចំណុចទី៣ នៃប្រការ១៦ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច។

ក្រុមហ៊ុនបរធនបាលដែលចាប់ផ្តើមធ្វើប្រតិបត្តិការអាជីវកម្មក្នុងរយៈពេលតិចជាង ៣ (បី) ឆ្នាំ ត្រូវគណនាចំនួនហានិភ័យប្រតិបត្តិការ ដោយបំប្លែងជាប្រាក់ចំណេញប្រតិបត្តិការជាចំនួនដែលមានរយៈពេល ៣ (បី) ឆ្នាំ តាមវិធីសាស្ត្រដែលកំណត់ដោយ **ន.ម.ធ.**។

ក្រុមហ៊ុនបរធនបាលត្រូវបន្ថែម ឬបន្ថយហានិភ័យប្រតិបត្តិការ ដូចមានក្នុងប្រការនេះ ដោយឆ្លុះបញ្ចាំងជាមួយចំនួនដែលបានកែសម្រួលដែលជាលទ្ធផលពីការវាយតម្លៃកម្រិតនៃការគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុនបរធនបាល តាមវិធីសាស្ត្រដែលកំណត់ដោយ **ន.ម.ធ.**។

**ប្រការ២៤.-**

**ន.ម.ធ.** អាចកែប្រែលក្ខខណ្ឌតម្រូវលើហានិភ័យដុល និងតម្រូវឱ្យក្រុមហ៊ុនបរធនបាលបង្កើនមូលធនប្រតិបត្តិការសុទ្ធដោយពិចារណាទៅលើកត្តាមួយចំនួន ដូចខាងក្រោម៖

១-ទ្រព្យសកម្មដែលមានលក្ខណៈអសន្ទនីយភាព។

២-ព័ត៌មានហានិភ័យ។

៣-ហានិភ័យផ្សេងៗដែលក្រុមហ៊ុនបរធនបាលអាចជួបប្រទះ។

## ជំពូកទី ៦
## ភាតព្វកិច្ចផ្តល់របាយការណ៍ស្ថានភាពមូលធនសុទ្ធ

**ប្រការ២៥.-**

ក្រុមហ៊ុនបរធនបាល ត្រូវផ្តល់ជូន **ន.ម.ធ.** យ៉ាងយូរត្រឹមថ្ងៃទី១០ នៃខែបន្ទាប់ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយ **ន.ម.ធ.** នូវរបាយការណ៍ប្រចាំខែ ដូចខាងក្រោម៖

១-របាយការណ៍តុល្យភាពសាកល្បងសង្ខេប។

២-របាយការណ៍សន្ទនីយភាពក្នុងទម្រង់ដែលកំណត់ដោយ **ន.ម.ធ.**។

ក្នុងករណីដែលកាលបរិច្ឆេទដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ត្រូវចំថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាកការងារដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុនបរធនបាលត្រូវផ្តល់របាយការណ៍នៅថ្ងៃធ្វើការបន្ទាប់។

**ប្រការ២៦.-**

**ន.ម.ធ.** អាចតម្រូវឱ្យក្រុមហ៊ុនបរធនបាលធ្វើការគណនា និងធ្វើរបាយការណ៍ស្ថានភាពមូលធនប្រតិបត្តិការសុទ្ធ ហានិភ័យដុល និងមូលធនភាគហ៊ុនិក គ្រប់ពេលវេលាទៅតាមការចាំបាច់។

**ប្រការ២៧.-**

ក្រុមហ៊ុនបរធនបាល ត្រូវរៀបចំរបាយការណ៍ និងព័ត៌មានអនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ច អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ អនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច ប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងប្រកាសនេះ ដោយប្រុងប្រយ័ត្ន និងដោយយកចិត្តទុកដាក់ ដើម្បីធានាឱ្យបាននូវភាពសុក្រឹតច្បាស់លាស់ និងពេញលេញ។ ប្រសិនបើមានកំហុសឆ្គង ឬការខ្វះខាតណាមួយត្រូវបានរកឃើញ បុគ្គលដែលបានផ្តល់របាយការណ៍នោះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ធ.** ជាបន្ទាន់ និងត្រូវផ្តល់សារជាថ្មីនូវរបាយការណ៍ និងព័ត៌មានដែលកែតម្រូវរួច។



P18. V

## ជំពូកទី ៧
## វិធានការកែតម្រូវបន្ទាន់

**ប្រការ២៨.-**

ក្នុងករណីដែលអនុបាតមូលធនសុទ្ធនៃក្រុមហ៊ុនបរធនបាលធ្លាក់ក្រោម ១៥០ (មួយរយហាសិប) ភាគរយ ក្រុមហ៊ុនបរធនបាលត្រូវចាត់វិធានការកែតម្រូវបន្ទាន់តាមអនុសាសន៍របស់ **ន.ម.ធ.**។

វិធានការកែតម្រូវបន្ទាន់ដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ សំដៅដល់វិធានការណាមួយ ឬទាំងស្រុង ដូចខាងក្រោម៖

១-ពង្រឹងធនធានមនុស្ស និងការគ្រប់គ្រងស្ថាប័ន។

២-កាត់បន្ថយចំណាយ។

៣-ដាក់កម្រិតលើសកម្មភាពនានាដែលនាំឱ្យមានការធ្លាក់ចុះអនុបាតមូលធនសុទ្ធ។

**ប្រការ២៩.-**

ក្នុងករណីដែលអនុបាតមូលធនសុទ្ធនៃក្រុមហ៊ុនបរធនបាលធ្លាក់ក្រោម ១២០ (មួយរយម្ភៃ) ភាគរយ ក្រុមហ៊ុនបរធនបាល ត្រូវចាត់វិធានការកែតម្រូវបន្ទាន់តាមការតម្រូវរបស់ **ន.ម.ធ.**។

វិធានការកែតម្រូវបន្ទាន់ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ សំដៅដល់វិធានការណាមួយ ឬទាំងស្រុង ដូចខាងក្រោម៖

១-ដាក់កម្រិតលើការកាន់កាប់ទ្រព្យសកម្មដែលមានហានិភ័យខ្ពស់ និងការលក់ ឬដោះដូរទ្រព្យសកម្ម។

២-បិទ និងបង្រួមបញ្ចូលគ្នានូវការិយាល័យអាជីវកម្ម ឬការដាក់កម្រិតលើការបើកការិយាល័យអាជីវកម្មថ្មី។

៣-ទាមទារឱ្យមានការផ្លាស់ប្តូរបុគ្គលិក។

៤-វិធានការទាំងអស់ដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការ២៨ នៃប្រកាសនេះ។

**ប្រការ៣០.-**

ក្នុងករណីដែលអនុបាតមូលធនសុទ្ធនៃក្រុមហ៊ុនបរធនបាលធ្លាក់ក្រោម ១០០ (មួយរយ) ភាគរយ ក្រុមហ៊ុនបរធនបាល ត្រូវចាត់វិធានការកែតម្រូវបន្ទាន់តាមការបញ្ជារបស់ **ន.ម.ធ.**។

វិធានការកែតម្រូវបន្ទាន់ដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ សំដៅដល់វិធានការណាមួយ ឬទាំងស្រុង ដូចខាងក្រោម៖

១-មិនបង្កើន ឬកាត់បន្ថយភ្លាមៗនូវសកម្មភាពជួញដូរឧបករណ៍ហិរញ្ញវត្ថុដែលមានហានិភ័យខ្ពស់ ឬសកម្មភាពហិរញ្ញប្បទាន។

២-បន្តប្រតិបត្តិការអាជីវកម្មទៅតាមលក្ខខណ្ឌដែលកំណត់ដោយ **ន.ម.ធ.**។

៣-វិធានការទាំងអស់ដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការ២៩ នៃប្រកាសនេះ។

ក្នុងករណីដែលក្រុមហ៊ុនបរធនបាល នៅតែមិនអាចបំពេញបាននូវអនុបាតមូលធនសុទ្ធ ដូចមានកំណត់ក្នុងកថាខណ្ឌទី២ នៃប្រការ៨ នៃប្រកាសនេះ ក្រុមហ៊ុនបរធនបាលត្រូវបានចាត់ទុកថា ស្ថិតក្នុងស្ថានភាពអសាធនីយ៍ ឬមានបញ្ហាផ្នែកហិរញ្ញវត្ថុ និងត្រូវចាប់ផ្ដើមអនុវត្តនីតិវិធីបន្តដូចមានបទប្បញ្ញត្តិពាក់ព័ន្ធនឹងបុននីតិសម្បទា និងការជម្រះបញ្ជីក្នុងវិស័យបរធនបាលកិច្ច។

**ប្រការ៣១.-**

**ន.ម.ធ.** ត្រូវមានមូលដ្ឋាន និងផ្តល់នូវមូលហេតុក្នុងការចាត់វិធានការដូចមានចែងក្នុងប្រការ២៨, ប្រការ២៩ និងប្រការ៣០ នៃប្រកាសនេះ ដល់ក្រុមហ៊ុនបរធនបាលដែលទទួលរងវិធានការកែតម្រូវបន្ទាន់។

**ប្រការ៣២.-**

ទោះបីជាក្រុមហ៊ុនបរធនបាលស្ថិតក្នុងស្ថានភាពដូចកំណត់ក្នុងកថាខណ្ឌទី១ នៃប្រការ២៨, កថាខណ្ឌទី១ នៃប្រការ២៩ ឬកថាខណ្ឌទី១ នៃប្រការ៣០ នៃប្រកាសនេះក៏ដោយ **ន.ម.ធ.** អាចលើកលែងជាបណ្តោះអាសន្ននូវវិធានការកែតម្រូវបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ ក្នុងករណី ក្រុមហ៊ុននោះត្រូវបានវាយតម្លៃថានឹងមិនធ្លាក់ក្នុងស្ថានភាពដែលតម្រូវឱ្យចាត់វិធានការកែតម្រូវបន្ទាន់ ដោយសារការបង្កើនដើមទុន ឬលក់ចេញនូវទ្រព្យសកម្មរបស់ខ្លួនជាដើម។

**ប្រការ៣៣.-**

ក្រុមហ៊ុនបរធនបាលដែលបានទទួលអនុសាសន៍ ការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រងដូចមានចែងក្នុងប្រការ២៨, ប្រការ២៩ ឬប្រការ៣០ នៃប្រកាសនេះ ត្រូវរៀបចំផែនការពង្រឹងការគ្រប់គ្រងដែលមានមាតិកា និងខ្លឹមសារឆ្លុះបញ្ចាំងការពង្រឹងការគ្រប់គ្រងស្របតាមអនុសាសន៍ ការតម្រូវ ឬការបញ្ជាដែលទទួលបាន និងត្រូវដាក់ជូន **ន.ម.ធ.** ដើម្បីសម្រេចក្នុងរយៈពេល ១ (មួយ)ខែ គិតចាប់ពីកាលបរិច្ឆេទទទួលបានអនុសាសន៍ ការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រងអាជីវកម្មនោះ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយ **ន.ម.ធ.**។

**ន.ម.ធ.** ត្រូវសម្រេចលើផែនការពង្រឹងការគ្រប់គ្រងដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ១ (មួយ)ខែ គិតចាប់ពីកាលបរិច្ឆេទទទួលបានផែនការពង្រឹងការគ្រប់គ្រងនោះ។

ក្នុងករណីដែលផែនការពង្រឹងការគ្រប់គ្រងមិនមានលក្ខណៈសមស្របតាមអនុសាសន៍ ការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រងអាជីវកម្ម ក្រុមហ៊ុនបរធនបាលត្រូវដាក់ជូន **ន.ម.ធ.** ឡើងវិញនូវផែនការពង្រឹងការគ្រប់គ្រងតាមការកំណត់របស់ **ន.ម.ធ.**។

**ប្រការ៣៤.-**

ការអនុវត្តផែនការពង្រឹងការគ្រប់គ្រងអាជីវកម្មត្រូវកំណត់ ដូចខាងក្រោម៖

១- រយៈពេល ៣ (បី)ខែ គិតចាប់ពីកាលបរិច្ឆេទសម្រេចលើផែនការពង្រឹងការគ្រប់គ្រងតាមអនុសាសន៍ពង្រឹងការគ្រប់គ្រងអាជីវកម្ម។

២- រយៈពេល ៦ (ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទសម្រេចលើផែនការពង្រឹងការគ្រប់គ្រងតាមការតម្រូវពង្រឹងការគ្រប់គ្រងអាជីវកម្ម។

៣- រយៈពេលអនុវត្តផែនការពង្រឹងការគ្រប់គ្រងអាជីវកម្មតាមការបញ្ជាពង្រឹងការគ្រប់គ្រងអាជីវកម្ម ត្រូវកំណត់ដោយ **ន.ម.ធ.**។

ក្នុងករណីដែលក្រុមហ៊ុនបរធនបាលបានទទួលអនុសាសន៍ពង្រឹងការគ្រប់គ្រងអាជីវកម្ម ស្របតាមប្រការ២៨ នៃប្រកាសនេះ ហើយក្នុងពេលកំពុងអនុវត្តផែនការពង្រឹងការគ្រប់គ្រងអាជីវកម្ម ក្រុមហ៊ុននោះបានទទួលការតម្រូវពង្រឹងការគ្រប់គ្រងអាជីវកម្មបន្ថែមទៀត រយៈពេលអនុវត្តផែនការពង្រឹងការគ្រប់គ្រងអាជីវកម្មមិនត្រូវលើសពី ១ (មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសម្រេចលើផែនការពង្រឹងការគ្រប់គ្រងអាជីវកម្មតាមអនុសាសន៍ដែលទទួលបាន។

**ប្រការ៣៥.-**

ក្នុងករណីដែលផែនការពង្រឹងការគ្រប់គ្រងអាជីវកម្មមិនបានសម្រេចតាមគោលដៅគ្រោងទុក ឬមានការលំបាកក្នុងការអនុវត្តតាមផែនការពង្រឹងការគ្រប់គ្រងអាជីវកម្ម ដោយសារមានការប្រែប្រួលបរិយាកាសអាជីវកម្ម ក្រុមហ៊ុនបរធនបាលអាចស្នើសុំការអនុញ្ញាតមក **ន.ម.ធ.** ដើម្បីកែប្រែមាតិកា និងខ្លឹមសារនៃផែនការពង្រឹងការគ្រប់គ្រងអាជីវកម្ម ដោយភ្ជាប់មកជាមួយនូវផែនការពង្រឹងការគ្រប់គ្រងថ្មី។

**ន.ម.ធ.** ត្រូវជូនដំណឹងអំពីការសម្រេចទទួលយកការស្នើសុំកែប្រែមាតិកា និងខ្លឹមសារនៃផែនការពង្រឹងការគ្រប់គ្រងអាជីវកម្ម បន្ទាប់ពីវាយតម្លៃទៅតាមករណីនីមួយៗ។ បទប្បញ្ញត្តិចែងក្នុងកថាខណ្ឌទី៣ នៃប្រការ៣៣ នៃប្រកាសនេះ ត្រូវអនុវត្តដូចគ្នាចំពោះក្រុមហ៊ុនបរធនបាល ដែលស្នើសុំកែប្រែមាតិកា និងខ្លឹមសារនៃផែនការពង្រឹងការគ្រប់គ្រងស្របតាមកថាខណ្ឌទី១ នៃប្រការនេះ។

**ប្រការ៣៦.-**

ក្រុមហ៊ុនបរធនបាលដែលបានទទួលការសម្រេចលើផែនការពង្រឹងការគ្រប់គ្រងអាជីវកម្ម ស្របតាមប្រការ៣៣ នៃប្រកាសនេះ ត្រូវដាក់ជូន **ន.ម.ធ.** នូវលទ្ធផលអនុវត្តផែនការពង្រឹងការគ្រប់គ្រងប្រចាំខែ ក្នុងរយៈពេលមិនលើសពីថ្ងៃទី១០ នៃខែបន្ទាប់ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយ **ន.ម.ធ.**។

ក្រុមហ៊ុនបរធនបាលដែលបានអនុវត្តផែនការពង្រឹងការគ្រប់គ្រងអាជីវកម្ម ត្រូវដាក់ជូន **ន.ម.ធ.** នូវលទ្ធផលអនុវត្តផែនការពង្រឹងការគ្រប់គ្រងអាជីវកម្មក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីរយៈពេលនៃការអនុវត្តផែនការនោះបានបញ្ចប់ដូចកំណត់ក្នុងប្រការ៣៤ នៃប្រកាសនេះ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយ **ន.ម.ធ.**។

**ប្រការ៣៧.-**

ក្នុងអំឡុងពេលនៃការអនុវត្តផែនការពង្រឹងការគ្រប់គ្រងអាជីវកម្ម ក្នុងករណីដែលក្រុមហ៊ុនបរធនបាលដែលបានទទួលអនុសាសន៍ ការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រងអាជីវកម្ម រក្សាបានឡើងវិញនូវអនុបាតមូលធនសុទ្ធយ៉ាងតិច ១៥០ (មួយរយហាសិប) ភាគរយ **ន.ម.ធ.** អាចពិចារណាសម្រេចបញ្ចប់វិធានការកែតម្រូវបន្ទាន់។



ភ្ជាប់ ✓

## ជំពូកទី ៨
## ទណ្ឌកម្ម

**ប្រការ៣៨.-**

ក្រុមហ៊ុនបរធនបាលដែលប្រើប្រាស់ប្រាក់តម្កល់ធានាអាជីវកម្មធ្វើការធានាផ្សេងៗ, មិនបង្ហាញខ្ទង់ក្រៅតារាងតុល្យការដល់ **ន.ម.ធ.**, មិនចាត់វិធានការកែតម្រូវបន្ទាន់តាមការបញ្ជារបស់ **ន.ម.ធ.**, មិនអនុវត្តតាមអនុសាសន៍ ការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រងរបស់ **ន.ម.ធ.**, មិនអនុវត្តកាតព្វកិច្ចជូនដំណឹងក្នុងករណីដែលមូលធនភាគហ៊ុនិកធ្លាក់ក្រោមលក្ខខណ្ឌតម្រូវលើមូលធនអប្បបរមា និងករណីរកឃើញកំហុសឆ្គង ឬការខ្វះខាតណាមួយនៃរបាយការណ៍ដែលផ្ញើជូន **ន.ម.ធ.**, មិនផ្តល់របាយការណ៍តុល្យភាពសាកល្បងសង្ខេប និងរបាយការណ៍សន្ទនីយភាពក្នុងទម្រង់ដែលកំណត់ដោយ **ន.ម.ធ.**, មិនគណនាអនុបាតមូលធនសុទ្ធប្រចាំខែ, មូលធនប្រតិបត្តិការសុទ្ធ, ហានិភ័យដុល, ហានិភ័យទីផ្សារ, ហានិភ័យភាគហ៊ុន ហានិភ័យអត្រាការប្រាក់, ហានិភ័យអត្រាប្តូរប្រាក់, ហានិភ័យឥណទាន និងហានិភ័យប្រតិបត្តិការដែលកំណត់ដោយ **ន.ម.ធ.** ដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលរងវិធានការរដ្ឋបាលពីមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដូចខាងក្រោម៖

- ការព្រមាន
- ការដឹកនាំកែតម្រង់
- ការកត់សម្គាល់ជាសាធារណៈ ហើយបញ្ជាឱ្យធ្វើការកែតម្រូវ
- ដាក់កំហិតលើការចាត់ចែង គ្រប់គ្រង និង/ឬថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ច
- ការដាក់កំហិតលើអាជ្ញាបណ្ណ/ការអនុញ្ញាត
- ការព្យួរអាជ្ញាបណ្ណ/ការអនុញ្ញាត
- ការដកហូតអាជ្ញាបណ្ណ/ការអនុញ្ញាត។

**ប្រការ៣៩.-**

បែបបទ និងនីតិវិធីនៃការចាត់វិធានការរដ្ឋបាល ដូចមានចែងក្នុងជំពូកនេះត្រូវអនុលោមតាមប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល និងពិន័យអន្តរការណ៍។

បុគ្គលដែលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដូចមានចែងក្នុងជំពូកនេះ អាចប្តឹងតវ៉ាតាមនីតិវិធីស្របតាមច្បាប់ស្តីពីបរធនបាលកិច្ច។

**ប្រការ៤០.-**

វិធានការរដ្ឋបាល ដូចមានចែងក្នុងជំពូកនេះ មិនរាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។



ព.ន.ប

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**ប្រការ៤១.–**

ន.ម.ធ. ត្រូវចេញគោលការណ៍ណែនាំអនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ច អនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ។

**ប្រការ៤២.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤៣.–**

អគ្គលេខាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ១៣កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា គ.ស. ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:-**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងយុត្តិធម៌
- -ធនាគារជាតិនៃកម្ពុជា
- -ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- -គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ. "ដើម្បីជូនជ្រាប"
- -ដូចប្រការ៤៣ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ